# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ ០៥៣៥ ន.គ.ស ស.ង.លា.

ថ្ងៃសុក្រ ១២រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង

## ស្តីពី

## ការស្នើសុំពន្យារពេលសម្រាប់ការបញ្ចប់ការងារសវនកម្មឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២

**និយ័តករគណនេយ្យនិងសវនកម្ម** នៃ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** សូមជម្រាបជូនម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញឱ្យបានជ្រាបថា៖ កាលបរិច្ឆេទនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មឯករាជ្យប្រចាំឆ្នាំ២០២២ មកនិយ័តករគណនេយ្យនិងសវនកម្ម បានផុតកំណត់ត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៣ នេះ សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលមានកាលបរិច្ឆេទបិទបញ្ជីគណនេយ្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ ដោយឡែក សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលមានការិយបរិច្ឆេទគណនេយ្យពិសេស នឹងត្រូវផុតកំណត់តាមគោលការណ៍រយៈពេល ៦ខែ និង១៥ថ្ងៃ គិតពីកាលបរិច្ឆេទបិទបញ្ចប់ការិយបរិច្ឆេទគណនេយ្យ។

អនុលោមតាមប្រកាសលេខ ៥៦៣ សហវ.ប្រក. ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវបានអនុញ្ញាតឱ្យស្នើសុំពន្យារពេលដើម្បីបញ្ចប់ការងារសវនកម្មឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន ដោយមានបញ្ជាក់ពីមូលហេតុសមស្រប។ ក្នុងន័យនេះ **និយ័តករគណនេយ្យនិងសវនកម្ម** សូមណែនាំដូចតទៅ៖

១. សំណើសុំពន្យារពេលត្រូវបញ្ជូនមកដល់និយ័តករគណនេយ្យនិងសវនកម្ម មិនឱ្យហួសថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ និងត្រូវបង់កម្រៃសេវាសាធារណៈស្របតាមប្រកាសលេខ ០០១ អ.ស.ហ. ប្រក. ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២២ ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម។

២. សំណើសុំអាចធ្វើឡើងដោយម្ចាស់សហគ្រាស ឬ ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬ ដោយក្រុមហ៊ុនសវនកម្មក្នុងនាមជាអ្នកទទួលអាណត្តិ។ រាល់សំណើសុំពន្យារពេលត្រូវភ្ជាប់មកជាមួយនឹងកិច្ចសន្យាសវនកម្ម។

៣. ការមិនអនុវត្តបានត្រឹមត្រូវស្របតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះសហគ្រាស និងអង្គភាពមិនស្វែករកប្រាក់ចំណេញ នឹងទទួលរងការពិន័យដូចបាន កំណត់នៅក្នុងអនុក្រឹត្យលេខ៧៩ អនក្រ.បក. ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមន្ត្រី **ន.គ.ស.** តាមរយៈលេខទូរសព្ទនិងតេឡេក្រាម៖ សម្រាប់សហគ្រាស ០៧០ ៩២៩ ២៣៧ និង សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ០៨១ ៦៤៤ ៦៦៣។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលជាប់កាតព្វកិច្ចទាំងអស់ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**អគ្គនាយក**

**ធ្វី ចារិន**

**ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សូមចូលរួមក្នុង Telegram Channel របស់និយ័តករគណនេយ្យនិងសវនកម្ម**